នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-May-2020, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ (ជាមួយឧបសម្ព័ន្ធសម្ងាត់ A1-K2)**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញាអន្តរជាតិ**

លោកស្រី Brenda J. HOLLIS

**ចម្លងជូន:**

**សហព្រះរាជអាជ្ញាជាតិ**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក សំ សុគង់

លោក ស៊ិន សូវ៉ន

Emmanuel JACOMY

Martine JACQUIN

Daniel MCLAUGHLIN

Nushin SARKARATI

**សហមេធាវី អោ អាន:**

មុំ សុជ្ស

Richard ROGERS

Göran SLUITER

លោកស្រី ជេត វណ្ណលី

លោក គឹម ម៉េងឃី

លោកស្រី ទី ស្រីណា

លោក វ៉េន ពៅ

Laure DESFORGE

Isabelle DURAND

Lyma NGUYEN

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមឆ្លើយតបទៅនឹងសំណើរបស់ អោ អាន សុំឱ្យសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងប័ណ្ណសារ[1] ដែលបានដាក់កាលពីខែមីនា ប៉ុន្តែមិនបានជូនដំណឹងទេរហូតដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០[2]។ ដូចបានពិភាក្សាខាងក្រោម សំណើរបស់ អោ អាន គួរបានបដិសេធ ដោយសារមិនទាន់ដល់ពេលផង និងដោយសារការខកខាននៃអង្គសេចក្តីផង។ និយាយដោយខ្លី អោ អាន មិនយល់ថា វិធាន៧៧ (១៣)(ខ) នៃវិធានផ្ទៃក្នុង មានអំណាចលុបលើវិធាន៧៧ (១៣)(ក)ទេ ដោយគាត់បានតវ៉ាទាំងខុសថា សំឡេងភាគច្រើនធម្មតាគួរតែមានអំណាចលុបលើ ជាជាងគោលជំហរស្ម័យប្រវត្តិដែលជាមូលដ្ឋាននៃប្រព័ន្ធច្បាប់ អ.វ.ត.ក ទាំងមូល ដែលនេះជាការយល់ខុសចំពោះគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយខុសចំពោះមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងទម្លាប់ករណីមានកំណត់សម្រាប់ការរំលត់រឿងក្តីនៅ អ.វ.ត.ក។

## II. ប្រវត្តិនីតិវិធី និងច្បាប់ជាធរមាន

2. ដូច ស.ច.ស បានជ្រាបច្បាស់ហើយថា អង្គជំនុំជម្រះសាលាដំបូង ("អ.ប.ជ") បានរកឃើញថា ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់ ស.ច.ស[3] ថាជារឿងខុសច្បាប់[4] ដោយសារបរាជ័យមិនអាចរកបាននូវសំឡេងភាគច្រើនលើសលុប ដើម្បីបដិសេធលើដីកាបញ្ជូនរឿងទៅជំនុំ

---

[1] ឯកសារ **D363** សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ("សំណើរបស់ អោ អាន")។

[2] *សូមមើល* សារអេឡិចត្រូនិកនៃសេចក្តីជូនដំណឹង ពីមន្ត្រីទទួលបន្ទុកសំណុំរឿង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១:២២ រសៀល។ ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") Michael Bohlander ត្រូវបានបន្តតំណែងឡើងវិញនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ក៏ដោយ (*សូមមើល* https://eccc.gov.kh/en/articles/statement-international-co,-investigating-judge-reinstated) ក៏គាត់មិនត្រូវបានបញ្ចូលទៅក្នុងបញ្ជីអ្នកទទួលសារអេឡិចត្រូនិកនៃសេចក្តីជូនដំណឹងនេះដែរ ក្នុងរយៈពេល១២ថ្ងៃក្រោយមក។

[3] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់")។ ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[4] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណារបស់ អ.ប.ជ") ផ្នែកសម្រេចសេចក្តី ត្រង់ KH 01634854។

ជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់[5]។ ក្រោយពេលដែលសេចក្ដីពិចារណារបស់ អ.ប.ជ ត្រូវបានជូនដំណឹង ភាគីនៃសំណុំរឿង ០០៤/២ ក៏បានចាប់ផ្ដើមដាក់សារណាជាមួយអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ដែលពាក់ព័ន្ធនឹងដំណើរការជំនុំជម្រះ និងស្ថានភាពនៃរឿងក្ដីនេះ[6]។ ទោះជាយ៉ាងណា អ.ជ.ស.ដ មិនធ្លាប់អនុញ្ញាតផ្ដល់មធ្យោបាយណាមួយសម្រាប់ដាក់ ឬជូនដំណឹងតាមអេឡិចត្រូនិកចំពោះសារណាទាំងនេះទេ។

3. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ដ បានផ្ញើសារអេឡិចត្រូនិកមួយ ជូនភាគី ក្នុងនាម អ.ជ.ស.ដ ដោយទទួលស្គាល់អំពីការទទួលបានឯកសារដែលភាគីបានបញ្ជូន ប៉ុន្តែថ្លែងថា សេចក្ដីពិចារណារបស់ អ.ប.ជ មិនបានជូនដំណឹងមក អ.ជ.ស.ដ ទេ ហើយសំណុំរឿង ឬក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏មិនបានបញ្ជូនមកដែរ[7]។

---

[5] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ ផ្នែកសម្រេចសេចក្ដី ត្រង់ KH 01634854។ ស.ព.អ កត់សំគាល់ថា សេចក្ដីពិចារណារបស់ អ.ប.ជ បានដាក់ជាសាធារណៈ ហើយសហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") យូ ប៊ុនឡេង ក៏ត្រូវបានបញ្ចូលក្នុងបញ្ជីអ្នកទទួលសារអេឡិចត្រូនិកនៃសេចក្ដីជូនដំណឹងដែរ (*សូមមើល* សារអេឡិចត្រូនិកនៃសេចក្ដីជូនដំណឹង ពីមន្ត្រីទទួលបន្ទុកសំណុំរឿង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៤:៥៣ រសៀល)។ នៅពេលនោះ ស.ច.ស.ជ គឺជាមន្ត្រី ឬសមាជិកបុគ្គលិកតែម្នាក់គត់ដែលនៅមាននៅការិយាល័យសហចៅក្រមស៊ើបអង្កេត (*សូមមើល* របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ UN Doc. A/74/359, ទំព័រ ១៧)។

[6] សំណើសុំពន្យារពេលកំណត់របស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង និងកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩(*ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ A1 (អង់គ្លេស) និង A2 (ខ្មែរ)*)។ លិខិតពីសហមេធាវីការពារក្ដីជូនចំពោះចៅក្រម អ.ជ.ស.ដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ (*ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ B1 (អង់គ្លេស) និង B2 (ខ្មែរ)*)។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ទាក់ទងនឹងការប្ដឹងឱ្យទទួលយកសំណុំរឿង ០០៤/២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ (*ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ C1 (អង់គ្លេស) និង C2 (ខ្មែរ)*)។ ការដាក់ជូនបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធសម្ងាត់ ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ (*ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ D1 (អង់គ្លេស) និង D2 (ខ្មែរ)*)។ សេចក្ដីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង (*ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ E1 (អង់គ្លេស) និង E2 (ខ្មែរ)*)។ *សូមមើលផងដែរ* ការដាក់ជូនបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ អោ អាន អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធសម្ងាត់ ១ និងចម្លើយតបរបស់គាត់ទៅនឹងការដាក់ជូនបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ (*ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ F*)។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្ដីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ (*ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ G1 (អង់គ្លេស) និង G2 (ខ្មែរ)*)។

[7] ឯកសារ **D359/36.2 & D360/45.2** ឯកសារភ្ជាប់ទី២ (សារអេឡិចត្រូនិក មានចំណងជើងថា "ព័ត៌មាន" ដែលបានបញ្ជូនដោយ លឹម ស៊ុយហុង ក្នុងនាម អ.ជ.ស.ដ), ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

4. ស.ព.អ បានធ្វើសារណាជាលាយលក្ខណ៍អក្សរជាបន្តបន្ទាប់ទៅកាន់ អ.ប.ជ ដោយបានស្នើសុំឱ្យ អ.ប.ជ ចាត់វិធានការរដ្ឋបាលទាំងអស់នេះ ខណៈដែល អោ អាន បានស្នើសុំឱ្យ អ.ប.ជ រក្សាទុកសំណុំរឿងនេះក្នុងបណ្ណសារ[8]។ អ.ប.ជ បានធ្វើសារណាទាំងអស់នេះទៅជាសាធារណៈ។

5. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ស.ព.អ បានស្នើសុំឱ្យ អ.ជ.ស.ដ បំពេញកិច្ចដើម្បីទទួលបានសិទ្ធិចូលមើលសំណុំរឿង[9]។ ក្រឡាញបញ្ជី អ.ជ.ស.ដ បានជូនដំណឹងជាបន្តបន្ទាប់ទៅភាគីតាមសារអេឡិចត្រូនិកថា ទោះបីជា អ.ជ.ស.ដ បានដឹងអំពីសេចក្តីពិចារណារបស់ អ.ប.ជ ដែលគេអាចរកបានជាសាធារណៈក៏ដោយ តែខ្លួននៅមិនទាន់ត្រូវ*បានជូនដំណឹងជាផ្លូវការ* ដោយ អ.ប.ជ អំពីសេចក្តីពិចារណានោះនៅឡើយ ហើយសំណុំរឿងក៏មិនទាន់បានបញ្ជូនមកខ្លួន។ សារអេឡិចត្រូនិកនេះបានបញ្ជាក់ថា អ.ប.ជ ត្រូវតែផ្តួចផ្តើមសកម្មភាពទាំងនោះ[10]។

6. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ភាគីបានទទួលអនុស្សរណៈអន្តរការិយាល័យ ពីចៅក្រមអន្តរជាតិនៃ

---

[8] ឯកសារ **D359/25 & D360/34** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/26 & D360/35** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យចាត់រាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/27 & D360/36** សំណើ [របស់ អោ អាន] សុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង០០៤/០២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/28 & D360/37** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់រាល់ វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។ ឯកសារ **D359/30 & D360/39** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង០០៤/២ ក្នុងបណ្ណសារ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ ("ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើសុំឱ្យរក្សាទុកក្នុងបណ្ណសារ")។ ឯកសារ **D359/31 & D360/40** ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង០០៤/២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[9] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការដើម្បីឱ្យបានចូលមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង០០៤/២ (អោ អាន) ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ H1 (ភាសាអង់គ្លេស) និង H2(ភាសាខ្មែរ))*។

[10] ឯកសារ **D359/36.8 & D360/45.8** ឯកសារភ្ជាប់លេខ ៨ (សារអេឡិចត្រូនិច ក្រោមចំណងជើងថា "ទាក់ទងនឹងសំណើរបស់ ស.ព.អ ចុះកាលបរិច្ឆេទនៅ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០") បានផ្ញើរចេញដោយក្រឡាបញ្ជីរបស់ អ.ជ.ស.ដ និងមន្ត្រីច្បាប់ លឹម ស៊ុយហុង ក្នុងនាម អ.ជ.ស.ដ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

អ.ប.ជ ដែលបានរៀបរាប់យ៉ាងលម្អិតអំពីការជាប់គាំងដែល - ភាគីមិនបានដឹង - បានកើតឡើងនៅក្នុង អ.ប.ជ ទាក់ទងនឹងសេចក្តីជូនដំណឹង និងការបញ្ជូនសំណុំរឿងនេះ[11]។ បួនថ្ងៃបន្ទាប់មក ប្រធាន អ.ប.ជ បានចេញជាឯកតោភាគីនូវអនុស្សរណៈមួយដែលបញ្ជាក់ច្បាស់ថាតាមការប៉ាន់ស្មានរបស់គាត់ អ.ប.ជ "បំពេញភារកិច្ចរបស់ខ្លួនរួចរាល់ហើយ" និងមិនតម្រូវឱ្យបំពេញកិច្ចរដ្ឋបាលណាមួយបន្ថែមទៀតឡើយ[12]។

7. ជាលទ្ធផលផ្ទាល់ចេញមកពីការបញ្ជាក់របស់ អ.ប.ជ ដែលថា ខ្លួនបានឈានដល់ភាពជាប់គាំងផ្នែករដ្ឋបាលហើយនោះ[13] ស.ព.អ បានដាក់សំណើរបស់ខ្លួនជាថ្មីស្នើសុំឱ្យ អ.ជ.ស.ដ ដំណើរការរឿងក្តី ០០៤/២ ទៅជំនុំជម្រះ[14]។ អ.ជ.ស.ដ បានឆ្លើយតបភ្លាមៗដោយបានលើកឡើង*ជាអាទិ៍* ថាការចេញសេចក្តីសម្រេចផ្លូវការ "មិនអាចធ្វើបានទេ" ខ្លួនមិនមានសំណុំរឿង និងឯកសារពាក់ព័ន្ធ ហើយសំណើដែលបានដាក់ដោយភាគីនានាមកកាន់ អ.ជ.ស.ដ នឹងត្រូវបង្វិលត្រឡប់ទៅវិញ[15]។ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ ឯកសារដែល ស.ព.អ បានបញ្ជូនទៅ អ.ជ.ស.ដ ត្រូវបានបង្វិលត្រឡប់មកវិញ ដែលដាក់ពាក្យសំគាល់ថា "បង្វិលត្រឡប់ទៅអ្នកផ្ញើ ៩-៤-២០២០"[16]។

---

[11] **D359/36 & D360/45** អនុស្សរណៈរបស់ចៅក្រមអន្តរជាតិ ទាក់ទងនឹងការបញ្ជូនសំណុំរឿង០០៤/២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈរបស់ចៅក្រមអន្តរជាតិ")។ **D359/36.1-36.8 & D360/45.1-45.8** ឯកសារភ្ជាប់ លេខ ១-៨។

[12] ឯកសារ **D359/37 & D360/46** អនុស្សរណៈរបស់ប្រធានថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈ ចុះថ្ងៃទី១៦ ខែមីនា") កថាខណ្ឌ ៥។

[13] ឯកសារ **D359/36 & D360/45** អនុស្សរណៈរបស់ប្រធាន កថាខណ្ឌ ៣៤-៣៧។ ឯកសារ **D359/37 & D360/46** អនុស្សរណៈរបស់លោកប្រធាន កថាខណ្ឌ ៥។

[14] សំណើសារជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការចាំបាច់ ដើម្បីជំរុញសំណុំរឿង០០៤/២ ទៅធ្វើសវនាការ រួមទាំងការចេញដីកាឱ្យបញ្ជូនជាបន្ទាន់នូវសំណុំរឿង០០៤/២ ទៅកាន់អង្គជំនុំជម្រះ សាលាដំបូង ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ I1 (អង់គ្លេស) និង I2 (ខ្មែរ))*។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងសំណើសារជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការចាំបាច់ ដើម្បីជំរុញសំណុំរឿង០០៤/២ ទៅធ្វើសវនាការ រួមទាំង ការចេញដីកាឱ្យបញ្ជូនជាបន្ទាន់នូវសំណុំរឿង០០៤/២ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធសម្ងាត់ J1 (អង់គ្លេស) និង J2 (ខ្មែរ))*។

[15] សេចក្តីថ្លែងការណ៍ របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្តីពីសំណុំរឿង០០៤/២ ពាក់ព័ន្ធនឹង អោ អាន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ អាចរកបានជាភាសាខ្មែរនៅតាម https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao។

[16] សារអេឡិចត្រូនិក ពីលោក គួច វណ្ណារិទ្ធិ ជូនចំពោះ ក.ស.ព មានចំណងជើងថា "ឯកសារដែលបានដាក់ជាសំណៅរឹង ទៅ អ.ជ.ស.ដ សំណុំរឿង ០០៤/២ ត្រូវបានបង្វិលត្រឡប់មក ក.ស.ព វិញ នៅរសៀលនេះ" ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ វេលា

8. នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ស.ព.អ បានដាក់បណ្ដឹងសាទុក្ខបន្ទាន់ទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ដោយបានសន្និដ្ឋានថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ និងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការរំលត់រឿងក្ដី ០០៤/២ ជាធរមាន ដែលបានធ្វើឲ្យខូចប្រយោជន៍របស់ ស.ព.អ និងភាគីផ្សេងៗទៀតនៃសំណុំរឿង ០០៤/២[17]។ បណ្ដឹងសាទុក្ខបន្ទាន់នោះបច្ចុប្បន្ននេះកំពុងស្ថិតនៅចំពោះមុខ អ.ជ.ត.ក និងមិនទាន់ត្រូវបានសម្រេចនៅឡើយ គិតត្រឹមកាលបរិច្ឆេទនៃការដាក់ឯកសារនេះ។

9. ច្បាប់ជាធរមាន ត្រូវបានចែងកំណត់ដូចខាងក្រោមចំពោះចំណុចដែលពាក់ព័ន្ធ។

## III. ចម្លើយតប

10. សំណើរបស់ អោ អាន ត្រូវតែបដិសេធចោលដោយហេតុថា វាធ្វើឡើងមុនពេលកំណត់ដោយយោងលើបណ្ដឹងសាទុក្ខរបស់ ស.ព.អ ដែលកំពុងរង់ចាំនៅចំពោះមុខ អ.ជ.ត.ក ដែលមានលទ្ធភាពមោឃៈសំណើនេះ។ ផ្ទុយទៅនឹងការលើកឡើងរបស់ អោ អាន ការិយាល័យសហចៅក្រមស៊ើបអង្កេត("ក.ស.ច.ស") មិនមែនជា"អង្គភាពតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែមួយគត់ ដែលមានអំណាចតាមវិធានផ្ទៃក្នុង ក្នុងការដោះស្រាយភាពជាប់គាំងបច្ចុប្បន្ននេះទេ"[18]។ ដូចដែល ស.ព.អ បានតវ៉ាទៅកាន់ អ.ជ.ត.ក បរាជ័យរបស់ អ.ជ.ស.ដ ក្នុងការបំពេញកិច្ចតាំងពីពេលដែលខ្លួនត្រូវបានប្ដឹងឲ្យទទួលយករឿងក្ដីនេះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ចេតនាដែលខ្លួនបានបញ្ជាក់នៅក្នុងសេចក្ដីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ក្នុងការបន្តភាពនៅស្ងៀមនោះ និងការបង្វិលជារូបវន្តត្រឡប់មកវិញនូវឯកសាររបស់ភាគី ដោយមិនបានធ្វើការពិចារណាលើបញ្ហាដែលអាចដោះស្រាយតាមផ្លូវតុលាការនៅក្នុងឯកសារទាំងនោះ បានរំលត់កិច្ចដំណើរការនីតិវិធីជាធរមាន និងមិនបានទុកឲ្យភាគីនូវឱកាសប្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមទេ[19]។ វិធានផ្ទៃក្នុងចែងថា

---

ម៉ោង ១:៥៩ រសៀល។ "បង្វិលត្រឡប់ទៅអ្នកផ្ញើ" បានទទួលឯកសារដែលបានបញ្ជូនពី អ.ជ.ស.ដ មកកាន់ ស.ព.អ វិញនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។

[17] បណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ("បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ទៅកាន់ អ.ជ.ត.ក") *(ភ្ជាប់ ជាឧបសម្ព័ន្ធសម្គាត់ K1 (អង់គ្លេស) និង K2 (ខ្មែរ))*។

[18] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ២, ២២។

[19] បណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ទៅកាន់ អ.ជ.ត.ក កថាខណ្ឌ ១-៣, ៥០-៧៦។

សេចក្តីសម្រេចបែបនេះរបស់ អ.ជ.ស.ដ គឺស្ថិតក្រោមការប្តឹងសាទុក្ខជាបន្ទាន់[20]។ ជាលទ្ធផល អ.ជ.ត.ក គឺជាអង្គភាពតុលាការដ៏សមស្របក្នុងការសម្រេចថាតើ សំណុំរឿង ០០៤/២ គួរដំណើរការទៅជំនុំជម្រះ ឬត្រូវរក្សារទុកក្នុងបណ្ណសារ។

11. សំណើរបស់ អោ អាន ត្រូវតែច្រានចោលផលដែរ ពីព្រោះវាបរាជ័យផ្នែកអង្គសេចក្តី។ ទីមួយ អោ អាន មើលរំលងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ដែលគាត់ខ្លួនឯងបានលើកយោង ដែលបែរជាផ្អែកលើការអះអាងថា វិធាន ៦៩(២)(ខ) គួរអនុវត្ត*ក្នុងករណីសមស្រប* ដោយហេតុថា មិនមានបទប្បញ្ញត្តិចែងអំពីកាលៈទេសៈនៃរឿងក្តីនេះទេ[21]។ ទោះជាយ៉ាងណា ក្របខណ្ឌច្បាប់ អ.វ.ត.ក កំណត់វិបាកនៃស្ថានភាពនេះ និងនិតិវិធីទាំងអស់នេះហើយដែលត្រូវតែអនុវត្តតាម មិនមែនវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុងឡើយ។ ជារួម មានតែសំឡេងភាគច្រើនលើសលុបដែលបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ដែលអាចរារាំងរឿងក្តីនេះមិនឲ្យដំណើរការទៅជំនុំជម្រះបាន[22]។ ការណ៍នេះត្រូវបានកំណត់ដោយវិធាន ៧៧(១៣)(ខ) ដែលជា *វិធានពិសេស* (lex specialis) ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុដូច្នេះ វាមានអានុភាពលើពាក្យពេចន៍ទូទៅនៃវិធាន ៧៧(១៣)(ក) ទាក់ទងនឹងដីកាសម្រេចផ្សេងៗ "ក្រៅពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[23]។ ដូចគ្នានឹង "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ"ដែរ "ដីកាសម្រេចលើកលែងចោទប្រកាន់" និង "ដីកាដំណោះស្រាយ" គឺជាពាក្យពេចន៍ដែលត្រូវបានកំណត់និយមន័យនៅក្នុងវិធានផ្ទៃក្នុង[24]។ ប្រសិនបើអ្នកធ្វើសេចក្តីព្រាងមានបំណងដោះស្រាយជាក់លាក់លើផលប៉ះពាល់នៃបរាជ័យរបស់ អ.ប.ជ ក្នុងការបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់នោះ ម្ល៉េះពួកគេច្បាស់ជាបានធ្វើដូច្នោះហើយ ប៉ុន្តែបានជ្រើសរើសមិនធ្វើដូច្នោះទេ[25]។ ផ្ទុយទៅវិញ វិធាន ៧៧(១៣)(ខ) អនុវត្តគោលបំណងច្បាស់លាស់របស់អង្គការសហប្រជាជាតិ ("អ.ស.ប") និងរាជរដ្ឋាភិបាលកម្ពុជា នៅពេលពួកគេបញ្ចប់

---

[20] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី ៩) ដូចដែលបានពិនិត្យឡើងវិញ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន") វិធាន ១០៤(៤)(ក)។

[21] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ១៣-១៤, ២០, ២១។

[22] *ផ្ទុយពី*ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ១៣-១៤, ១៨, ២០។

[23] ពាក្យឡាតាំងថា lex specialis (វិធានពិសេស) យោងទៅរកទ្រឹស្តីមួយទាក់ទងនឹងការបកស្រាយច្បាប់ ដែលយោងតាមវិធាននេះ ច្បាប់ដែលគ្រប់គ្រងលើប្រធានបទជាក់លាក់ (*lex specialis* (វិធានពិសេស)) លុបលើច្បាប់ដែលគ្រាន់តែគ្រប់គ្រងលើបញ្ហាទូទៅ (*lex generalis* (វិធានទូទៅ))។

[24] *សូមមើល* វិធានផ្ទៃក្នុង ទំព័រទី ៨៣-៨៤។

[25] អោ អាន ទទួលស្គាល់ថា គ្មានបទប្បញ្ញត្តិបែបនេះទេ។ *សូមមើល* **D363** សំណើរបស់ អោ អាន កថាខណ្ឌ ១៣, ២១។

កិច្ចព្រមព្រៀង អ.វ.ត.ក[26]។ ចេតនានេះក៏ត្រូវបានបង្ហាញភ័ស្តុតាងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ដែលចែងថា នៅពេលដែលសហព្រះរាជអាជ្ញា ឬ ស.ច.ស ខ្វែងយោបល់គ្នាលើ ការដំណើរការរឿងក្តីទៅមុខ រឿងក្តីនោះបន្តទៅដំណាក់កាលបន្ទាប់ទៀត ប្រសិនបើមិនមានសំឡេង ភាគច្រើនរបស់ អ.ប.ជ រារាំងដំណើរការទៅមុខរបស់វានោះទេ[27]។ អនុលោមតាមបទប្បញ្ញត្តិទាំង អស់នេះ ក៏ដូចជាវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង អ.ជ.ស.ដ ត្រូវបានប្តឹងឱ្យទទួលយករឿងក្តី

---

[26] ឯកសារ **D324.30** លិខិតពីលោកអគ្គលេខាធិការ អ.ស.ប ជូនទៅ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២000 កំណត់សម្គាល់ដែលបានភ្ជាប់ជាឧបសម្ព័ន្ធពីលោក Hans Corell ជូនទៅលោកអគ្គលេខាធិការ ប្រធានបទ៖ ការអំពាវនាវជាបន្ទាន់ពីប្រទេសកម្ពុជា - ជម្រើសនានាដើម្បីដោះស្រាយការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបសួរ/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២000 EN 01326090 (នៅថ្ងៃជាមួយគ្នាដែល អ.ស.ប បានផ្តល់ជាដំបូងនូវមាត្រា ៧(៤) ដែលមានពាក្យពេចន៍ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា លោក Hans Corell ដែលជាអគ្គលេខាធិការរង ខាងកិច្ចការច្បាប់ និង ក្រុមប្រឹក្សាអ្នកច្បាប់របស់ អ.ស.ប បានកត់ត្រានូវការសន្ទនាគ្នាជាមួយនឹងលោក សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមចរចារបស់រាជរដ្ឋាភិបាលកម្ពុជា ដោយច្រានចោលការអំពាវនាវរបស់គាត់ឱ្យមានលក្ខខណ្ឌតម្រូវមតិភាគ ច្រើនដាច់ខាតដើម្បី *អនុញ្ញាត* ឱ្យមានការបន្តកិច្ចស៊ើបសួរ ឬ ការចោទប្រកាន់។ លោក Hans Corell បានពន្យល់ថា យន្តការនៃការខ្វែងយោបល់គ្នាដូចដែលបានព្រាងនេះ មានន័យថា “លោក/អ្នក ចាំបាច់ត្រូវការមតិភាគច្រើនដាច់ខាតដើម្បីបញ្ឈប់កិច្ចស៊ើបសួរ ឬ ការចោទប្រកាន់”)។ ឯកសារ **D324.36** សេចក្តីថ្លែងការណ៍ដោយលោក អគ្គលេខាធិការរង Hans Corell នៅពេលចាកចេញពីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៣ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៣ EN 01326112។ *សូមមើលផងដែរ* ឯកសារ **D359/3/1.1.43** លោក David Scheffer “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទី៣ វ៉ូលូម III ឆ្នាំ២០០៨ ទំព័រទី ២៩៦ (EN 01598756) (លោក David Scheffer ឯកអគ្គរដ្ឋទូតគោចរ ស.រ.អា សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម មានការជាប់ទាក់ទងយ៉ាងសំខាន់នៅក្នុងកិច្ចចរចា អ.វ.ត.ក និងបានបញ្ជាក់នូវទស្សនៈដូចគ្នាថា៖ “មានវិធីតែមួយប៉ុណ្ណោះដែល ការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ *ត្រូវបានបញ្ឈប់* គឺថា ប្រសិនបើ [អ.ប.ជ] សម្រេចដោយសំឡេងភាគច្រើនដាច់ខាតថាវាត្រូវតែបញ្ឈប់។ សនិទានភាពនៅពីក្រោយនីតិវិធីនេះ គឺថា វារារាំង [ស.ច.ស] មួយ ឬ សហព្រះរាជអាជ្ញាមួយ មិនឱ្យរាំងខ្ទប់កិច្ចស៊ើបសួរ ឬ ការចោទប្រកាន់ រៀងៗខ្លួន ដោយការខកខានមិនបាន ឈានដល់ការព្រមព្រៀងគ្នាជាមួយនឹងដៃគូរបស់ខ្លួន ឬ ក៏គ្រាន់តែឃ្លាតចាកពីកិច្ចស៊ើបសួរ ឬ ការចោទប្រកាន់ បណ្តាលមកពីនយោបាយ ឬ ឥទ្ធិពលប្រភេទផ្សេងៗទៀត” (សង្កត់ន័យបន្ថែម))។

[27] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ (“កិច្ចព្រមព្រៀង អ.វ.ត.ក”) មាត្រា ៧(៤)។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តី ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ អ.វ.ត.ក”) មាត្រា ២៣ថ្មី។

០០៤/២ នេះ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[28] ហេតុដូច្នេះហើយ រឿងក្ដីនេះមិនគួរត្រូវរក្សាទុកក្នុងបណ្ណសារទេ។

12. ផ្ទុយទៅវិញ សំណើរបស់ អោ អាន មានបំណងដាក់ចេញនូវ "គោលជំហរស្វ័យប្រវត្តិ" ថ្មីមួយ ដែលខុសទៅនឹងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ដោយបានលើកឡើងថា ក្នុងពេលអវត្តមានសំឡេងភាគច្រើនលើសលុប ទស្សនៈសំឡេងភាគច្រើនធម្មតាដែលបានតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលុបលើ[29]។ ការពឹងផ្អែកលើទស្សនៈសំឡេងភាគច្រើនបែបនេះ គឺមិនត្រឹមត្រូវទេ ដោយយោងទៅលើរចនាសម្ព័ន្ធពិសេសប្លែកពីគេរបស់ អ.វ.ត.ក។ ទស្សនៈសំឡេងភាគច្រើនធម្មតាមិនមានទម្ងន់ជាកត្តាកំណត់នៅ អ.វ.ត.ក ដូចដែលវាមាននៅឯតុលាការផ្សេងទៀតនោះទេ។ ផ្ទុយទៅវិញ អ្នកបង្កើតតុលាការនេះ បានអនុវត្តវិធានស្ដីពីសំឡេងភាគច្រើនលើសលុប ដើម្បីការពារកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងឥទ្ធិពល ឬការជ្រៀតជ្រែកពីខាងក្រៅ និងបានបង្កើតគោលជំហរស្វ័យប្រវត្តិនេះឡើងដើម្បីឱ្យរឿងក្ដីមួយអាចមិនត្រូវបានគេបង្អាក់ ប្រសិនបើសំឡេងភាគច្រើនលើសលុបមិនអាចរកបាន[30]។ វិធានស្ដីពីសំឡេងភាគច្រើនលើសលុប និងគោលជំហរស្វ័យប្រវត្តិនេះ ត្រូវបានព្រមព្រៀងគ្នាដោយ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា និងបានអនុវម័តិជាច្បាប់[31]។ ផ្ទុយទៅនឹងអំណះអំណាងរបស់ អោ អាន ការប្រកាន់ខ្ជាប់គោលការណ៍ត្រឹមត្រូវតាមច្បាប់ទាំងនេះ មិនរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ចឡើយ[32]។

13. ការអះអាងគ្មានមូលដ្ឋានរបស់ អោ អាន ដែលថា អ្នកឈ្នះក្នុងការប្រគួតប្រជែងដាក់ដីកាដំណោះស្រាយគួរមានអានុភាពលុបលើ គឺមិនមានអង្គសេចក្ដីដូចគ្នា។ គាត់មិនបានចង្អុលបង្ហាញអ្វីមួយនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង ឬយុត្តិសាស្ត្រណាមួយ ដែលគាំទ្រចំពោះអំណះអំណាងក្លែងក្លាយរបស់គាត់ឡើយ[33]។ ទោះជាយ៉ាងណា ស.ព.អ កត់សម្គាល់ថា ការបោះត្រា

---

[28] *ផ្ទុយពី* **D363** សំណើរបស់ អោ អាន កថាខណ្ឌ ២ និង ២២ (បានអះអាងថា អ.ជ.ស.ជ តាមច្បាប់មិនត្រូវបានប្ដឹង ឱ្យទទួលយកសំណុំរឿងនេះទេ)។ កថាខណ្ឌ ២០ (បានអះអាងថា តាមទម្រង់ច្បាប់គឺមិនអាចដោះស្រាយការជាប់គាំងនេះ បាន ទេ)។

[29] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ១៨-២០។

[30] *សូមមើល ឧទា.* ឯកសារ **D359/3/1.1.43** លោក David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពផ្សាយលើកទី៣ វ៉ុល្លូមIII ឆ្នាំ២០០៨ ទំព័រ២៤៦ (EN 01598756)។

[31] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។

[32] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ២០, ២៥។

[33] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ២០។

នៅលើដីកាដំណោះស្រាយ សបញ្ជាក់ឲ្យឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ មិនត្រូវបានដាក់មុននោះទេ៖ គឺ ស.ច.ស បានដាក់ដីកាដំណោះស្រាយទាំងពីររួមគ្នាក្នុងពេលតែមួយ នៅម៉ោង ៨:១០នាទីព្រឹក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨[34]។

14. អោ អាន ក៏យល់ច្រឡំផងដែរ អំពីគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*[35]។ អត្ថិភាពនៃគោលជំហរស្វ័យប្រវត្តិ គឺផ្ទុយគ្នាស្រឡះទៅនឹងការអះអាងរបស់ អោ អាន ថា "ការជាប់គាំង និងភាពមិនប្រាកដប្រជាទាំងអស់ត្រូវតែដោះស្រាយក្នុងប្រយោជន៍ [របស់គាត់]"[36]។ ជាងនេះទៀត គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាផលវិបាកនៃសច្ចធារណ៍នៃនិរទោស និងជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវដែលថា ពិរុទ្ធភាពត្រូវតែរកឲ្យឃើញហួសពីវិមតិសង្ស័យ *នៅពេលជំនុំជម្រះ*[37]។ គោលការណ៍នេះត្រូវបានអនុវត្តនៅពេលដែលការសង្ស័យផ្នែកអង្គហេតុមិនត្រូវបានលុបបំបាត់ដោយភ័ស្តុតាង ដែលបង្ហាញនៅពេលជំនុំជម្រះ ឬនៅក្នុងករណីកម្រមាននៃការសង្ស័យនៅក្នុងច្បាប់*សារធាតុ*[38]។ ម្យ៉ាងវិញទៀត គោលការណ៍*វិមតិសង្ស័យត្រូវបានជា*

---

[34] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ (សំណៅជាភាសាខ្មែរ) ក្បាលលិខិត។ ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (សំណៅជាភាសាអង់គ្លេស) ក្បាលលិខិត។

[35] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ១៥, ១៨, ២០។

[36] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ២០ (មានសម្រង់) កថាខណ្ឌ ១៥។

[37] សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ (សេចក្តីសម្រេចលើការដោះលែង ខៀវ សំផន) កថាខណ្ឌ ៣១។ *រដ្ឋអាជ្ញា ទល់នឹង Limaj និងគូកន* សំណុំរឿង IT-03-66-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ២១។ *Renzaho ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿង ICTR-97-31-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៧៤ (កត់សម្គាល់ថា គោលការណ៍នេះអនុវត្តចំពោះការរកឃើញនានាដែលត្រូវការសម្រាប់ការផ្តន្ទាទោស)។ *រដ្ឋអាជ្ញា ទល់នឹង Delalić និងគូកន* សំណុំរឿង IT-96-21-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ("សាលក្រម *Čelebići*") កថាខណ្ឌ ៦០១ ("នៅចុងបញ្ចប់នៃសំណុំរឿង ជនជាប់ចោទត្រូវមានសិទ្ធិទទួលបានប្រយោជន៍ពីការសង្ស័យនេះ ថាតើបទល្មើសត្រូវបានបញ្ជាក់ភ័ស្តុតាង ឬយ៉ាងណា")។

[38] *សូមមើល ឧទា.* លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ មាត្រា ២២(២)។ *សូមមើលបន្ថែមទៀត រដ្ឋអាជ្ញា ទល់នឹង Gbagbo និង Blé Goudé* សំណុំរឿង ICC-02/11-01/15-744 សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Laurent Gbagbo និងលោក Charles Blé Goudé ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី I ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ក្រោមចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំដាក់បញ្ចូលសក្ខីកម្មដែលបានកត់ត្រាពីមុន ក្រោមវិធាន ៦៨(២)(ខ) និង ៦៨(៣)" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៣។

*ប្រយោជន៍ដល់ជនជាប់ចោទ* ទាក់ទងទៅនឹងការសង្ស័យអំពីពិរុទ្ធភាពចុងក្រោយរបស់ជនជាប់ចោទ មិនមែនការជាប់គាំងផ្នែករដ្ឋបាលនៅក្នុងដំណាក់កាលមុនពេលជំនុំជម្រះទេ គឺមិនទាក់ទងទៅនឹងការកំណត់ណាមួយអំពីពិរុទ្ធភាព ឬនិរទោសនោះទេ[39]។

15. គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវបានអនុវត្តយូរៗម្តងក្នុងពេលមានភាពមិនច្បាស់លាស់នៃច្បាប់ ប៉ុន្តែភាពអាចអនុវត្តបានរបស់វា ត្រូវបានកំណត់ត្រឹមការសង្ស័យដែលនៅសេសសល់ បន្ទាប់ពីការប្រើវិធាននៃការបកស្រាយច្បាប់ស៊ីវិល[40]។ រាល់អត្ថបទច្បាប់ត្រូវស្ថិតក្រោមការបកស្រាយ ហើយអង្គហេតុដែលថា សេណារីយ៉ូជាក់លាក់មួយអាចមិនត្រូវបានគ្របដណ្តប់ច្បាស់លាស់ដោយច្បាប់នោះ មិននាំឲ្យមាន"ការសង្ស័យ" ដែលតាមរយៈការសង្ស័យនេះ ចុងចោទតែងតែទទួលបានអត្ថប្រយោជន៍ជានិច្ចនោះទេ។ អ.ជ.ត.ក បានសម្រេចថា "គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ ក្នុងការដោះស្រាយលើ *ភាពខ្វះចន្លោះ*នៃច្បាប់ឡើយ"[41]។

16. ខណៈដែលគោលជំហររបស់ ស.ព.អ គឺថា មិនមាន*ភាពខ្វះចន្លោះនៃច្បាប់* ត្រូវបានបង្ហាញនៅក្នុងរឿងក្តីនេះ ដោយហេតុថា គោលជំហរស្វ័យប្រវត្តិអាចអនុវត្តបានយ៉ាងច្បាស់លាស់ នៅពេលដែលបញ្ហានីតិវិធីមិនត្រូវបានដោះស្រាយដោយវិធានផ្ទៃក្នុង នោះវិធាន ២ នៃវិធានផ្ទៃក្នុង ណែនាំអង្គជំនុំ

---

[39] *សូមមើល ឧទា.* ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ៨៥ ("ទោះបីជានៅដំណាក់កាលមុនអង្គសេចក្តីមានភាពចាំបាច់ត្រូវមានលក្ខខណ្ឌលើសពីសូចនាករបញ្ជាក់ ឬ ភាពមន្ទិលសង្ស័យដើម្បីបញ្ជូនជនម្នាក់ទៅជំនុំជម្រះបានក៏ដោយ ភស្តុតាងដែលប្រមូលបានពុំទាន់ចាំបាច់ត្រូវបញ្ជាក់ពីពិរុទ្ធភាពឲ្យបានជាក់លាក់នៅឡើយនោះទេ") កថាខណ្ឌ ១៦៣ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣២៣។

[40] សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើការដោះលែង ខៀវ សំផន កថាខណ្ឌ ៣១ (បានពន្យល់ថា វិធានប្រព័ន្ធច្បាប់ស៊ីវិលនៃការបកស្រាយច្បាប់ត្រូវពិចារណាលើ "ពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ")។ សាលក្រម *Čelebići* កថាខណ្ឌ ៤១៣ ("អានុភាពនៃការបកស្រាយដ៏តឹងរឹងនៃបទប្បញ្ញត្តិនៃលក្ខន្តិកៈព្រហ្មទណ្ឌនេះ គឺថា កាលណាមានពាក្យពេចន៍មួយដែលមានមន្ទិលសង្ស័យ ឬ ប្រយោគដែលមិនច្បាស់លាស់ បន្សល់ទុកឲ្យមានការសង្ស័យដ៏សមហេតុសមផលមួយចំពោះនិយមន័យរបស់វា *ដែលវិធានដែលប្រើដើម្បីបកស្រាយបរាជ័យក្នុងការដោះស្រាយ* ផលប្រយោជន៍នៃការសង្ស័យនេះត្រូវបានផ្តល់ទៅឲ្យបុគ្គលនោះ ហើយប្រឆាំងនឹងអង្គនីតិបញ្ញត្តិដែលខកខានមិនបានពន្យល់ខ្លួនវាផ្ទាល់។ នេះគឺជាមូលហេតុដែលលក្ខន្តិកៈព្រហ្មទណ្ឌដែលមិនច្បាស់លាស់ ត្រូវបកស្រាយ*ប្រឆាំងទៅនឹងអ្នកព្រាង*" (គូសបញ្ជាក់បន្ថែម))។

[41] សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើការដោះលែង ខៀវ សំផន កថាខណ្ឌ ៣១។

ជម្រះឲ្យសម្រេចលើបញ្ហានោះដោយប្រកាន់ខ្ជាប់ទៅតាមច្បាប់កម្ពុជា និងវិធាននីតិវិធីដែលពាក់ព័ន្ធ។ វិធានពាក់ព័ន្ធទាំងនេះ រួមបញ្ចូលទាំងមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ដែលកំណត់ថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"[42]។ ជាការគួរឲ្យកត់សម្គាល់ វិធាន២ មិនផ្តល់ឲ្យមានការសន្និដ្ឋានជាស្វ័យប្រវត្តិក្នុងប្រយោជន៍ដល់ជនជាប់ចោទនោះទេ។ ផ្ទុយទៅវិញ វិធាននេះណែនាំអង្គជំនុំជម្រះឲ្យផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងនៅក្នុងវិធាន ២១ ដែលការពារសិទ្ធិមិនមែនតែសិទ្ធិរបស់ជនជាប់ចោទទេ ប៉ុន្តែថែមទាំងសិទ្ធិរបស់ជនរងគ្រោះផងដែរ និងអាណត្តិដែលកំណត់ឲ្យមានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវយុត្តិធម៌ ដែលរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគី *ទាំងអស់*។ ដើម្បី "ដោះស្រាយភាពជាប់គាំង និងភាពមិនប្រាកដប្រជាទាំងអស់" ក្នុងប្រយោជន៍របស់ អោ អាន ដូចដែលគាត់អះអាងថាតម្រូវឲ្យធ្វើនោះ[43] នឹងធ្វើឲ្យខូចតុល្យភាពនេះជាពិសេស ការចូលរួមដ៏មានអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មនានា អនុលោមតាមការស្វែងរកឲ្យមានការផ្សះផ្សាជាតិរបស់ អ.វ.ត.ក[44]។

17. ជាចុងក្រោយ អោ អាន យល់ច្រឡំចំពោះមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដោយអះអាងទាំងខុសថា មាត្រានេះបង្គាប់ថា សំណុំរឿង ០០៤/២ ត្រូវបានរំលត់យ៉ាងមានប្រសិទ្ធិភាពចាប់តាំងពីថ្ងៃទី១៩

---

[42] វិធាន ២ នៃវិធានផ្ទៃក្នុង។

[43] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ២០ (មានការដកស្រង់) កថាខណ្ឌ ១៥។

[44] សំណុំរឿង០០២-ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៤-៦៥។ កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា។ *កត់សម្គាល់ថា* ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីបញ្ហាស្តីពីការរំលោភលើសិទ្ធិរបស់បណ្តឹងរដ្ឋប្បវេណីយ៉ាងធ្ងន់ធ្ងរ និងច្រំដែលៗនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ រួមទាំងសិទ្ធិក្នុងការទទួលបានការធ្វើសវនាការ មានតំណាង ភាពជាក់លាក់ខាងផ្លូវច្បាប់ និងតម្លាភាព និងសាធារណភាព នៃកិច្ចដំណើរការនីតិវិធី។ *កត់សម្គាល់បន្ថែមទៀតថា* ទោះបីជាបញ្ហាទាំងនេះត្រូវបាន លើកឡើងនៅក្នុង ឯកសារ **D359/33 & D360/42** សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់ នានារបស់អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ កថាខណ្ឌ ២, ៤, ២៧-៤៥ សារណា នេះត្រូវបានដាក់បន្ទាប់ពីលោកប្រធាន អ.ប.ជ បានប្រកាសថា អ.ប.ជ នឹងមិនចាត់ការបន្ថែមទៀតទេ ហើយរហូតមកទល់ សព្វថ្ងៃនេះ អ.ប.ជ មិនបានវិនិច្ឆ័យសេចក្តីលើបញ្ហាទាំងនេះទេ។ សារណា ពន្យល់ថា អ.ប.ជ គឺគ្រាន់តែជាអង្គជំនុំជម្រះមួយដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សំណើដើម្បីការពារនូវសិទ្ធិរបស់ខ្លួន ដោយហេតុថា មិនមានមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរូបណា ត្រូវបានទទួលស្គាល់ដោយការិយាល័យរដ្ឋបាល ឬ អ.ប.ជ នោះទេ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានគោលជំហរស្វ័យប្រវត្តិក្នុងការធ្វើសារណានៅចំពោះមុខ អ.ជ.ស.ដ ឬ អ.ជ.ត.ក ឡើយ (គឺមានតែមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នេះនៅតំណាក់កាលជំនុំជម្រះលើអង្គសេចក្តី និងហួសពីនោះទៀត)។

ខែធ្នូ ឆ្នាំ២០១៩[45] មកម្ល៉េះ។ តាមន័យនៃភាសាខ្មែរ មាត្រា ៣៨ ចែងថា *"វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"*[46] មិនមែនថា ការសង្ស័យ*ណាមួយ*[47] ដូច អោ អាន បានអះអាងទេ។ ការប្រើពាក្យរបស់រដ្ឋធម្មនុញ្ញនៃពាក្យ "វិមតិសង្ស័យ" ជាការពង្រឹងបន្ថែមលើគោលជំហររបស់ ស.ព.អ ថាគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺអនុវត្តបានជាចំបង គឺនៅក្រោយពេលនៃការវាយតម្លៃលើពិរុទ្ធភាពរបស់ជនជាប់ចោទនៅ *ឯសវនាការជំនុំជម្រះ* រួចហើយ ការសង្ស័យនៅតែមាន ដោយសារដំណាក់កាលសវនាការជំនុំជម្រះ គឺជាដំណាក់កាលដែលបន្ទុកនៃការបង្ហាញភ័ស្តុតាងត្រូវបង្ហាញឲ្យហួសពី "វិមតិសង្ស័យ"។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានពង្រឹងលើគោលជំហរនេះបន្ថែមទៀត ដោយហេតុថា "វិមតិសង្ស័យ" និង "ផលប្រយោជន៍ដែលទទួលបានពីវិមតិសង្ស័យនេះ" ត្រូវបានប្រើតែនៅក្នុងបរិបទនៃពិរុទ្ធភាពរបស់បុគ្គលដែលត្រូវបានកាត់ទោសហើយ (ទណ្ឌិត) ប៉ុណ្ណោះ[48]។ លើសពីនេះ នីតិវិធីកម្ពុជាចែងថា បណ្តឹងអាជ្ញាអាចត្រូវបានរលត់តែក្នុងករណីមរណភាពនៃជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ និងអាជ្ញាអស់ជំនុំ[49]។ ដោយសារសំណុំរឿង ០០៤/២ មិនត្រូវបានរំលត់ដោយមូលដ្ឋានណាមួយនៃទឡ្ហីករណ៍ទាំងនេះ ហើយ អ.ជ.ត.ក និង អ.ជ.ស.ដ ទាំងពីរបានសម្រេចថា អ.វ.ត.ក គ្មានសិទ្ធិអំណាចក្នុងការរំលត់រឿងក្តីដោយសារមូលហេតុផ្សេងនោះ[50]

---

[45] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ១។

[46] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុមតិនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៣៨ (សង្កត់ន័យដើម)។

[47] ឯកសារ **D363** សំណើរបស់ អោ អាន កថាខណ្ឌ ១៥។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ៣៥០-៣៥១ (ពាក់ព័ន្ធនឹងសេចក្តីប្រកាសអំពីពិរុទ្ធភាព ដោយកត់សំគាល់ថា "វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច") មាត្រា ៤៤៥ ("បណ្តឹងសើរើរឿងក្តីអាចធ្វើបានតែនៅក្នុងករណីដូចតទៅប៉ុណ្ណោះ ៖ [...] ៤. កាលណាមានអង្គហេតុថ្មី ឬលិខិត ឬភ័ស្តុតាងថ្មីដែលនាំឲ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត")។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៧។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំង, ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ មាត្រា ៦ ("L'action publique pour l'application de la peine s'éteint par la mort du prévenu, la prescription, l'amnistie, l'abrogation de la loi pénale et la chose jugée." បកប្រែក្រៅផ្លូវការ៖ កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានរំលត់តាមរយៈមរណភាពនៃចុងចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ")។

[50] សំណុំរឿង ០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២, កថាខណ្ឌ៣៨។ សំណុំរឿង ០០២-ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១

ការដាក់បញ្ចូលសំណុំរឿងនេះទៅក្នុងប័ណ្ណសារក្នុងដំណាក់កាលនេះតាមអ្វីដែល អោ អាន បានស្នើសុំ គឺជារឿងឆាប់ពេក និងមិនសមស្រប។

## IV. សេចក្តីសន្និដ្ឋាន

18. ស.ព.អ សន្និដ្ឋានថា ស.ច.ស គួរតែបដិសេធសំណើសុំរបស់ អោ អាន ដោយសារវាមិនទាន់ដល់ពេលផង និងដោយសារគ្មានអង្គសេចក្តីអាស្រ័យលើមូលហេតុទាំងអស់ដូចបានជម្រាបជូនខាងលើផង។ តាមជម្រើសផ្សេងពីនេះ ប្រសិនបើ ស.ច.ស ជ្រើសយកជម្រើសដើម្បីបង្អង់សេចក្តីសម្រេចរបស់ខ្លួនដោយរង់ចាំដំណោះស្រាយលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ស.ព.អ សិន ហើយ*ក្នុងន័យអំណះអំណាង* បើសិនជា អ.ជ.ត.ក សម្រេចថា បណ្តឹងសាទុក្ខអាចទទួលយកបាន ស.ព.អ សន្និដ្ឋានថា សំណើសុំរបស់ អោ អាន គួរតែត្រូវបានបដិសេធដដែល ដោយហេតុថា បន្ទាប់មកវានឹងតម្រូវឲ្យ ស.ច.ស បញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៧៧(១៣)(ខ), ៧៩(១) និងគោលជំហរស្វ័យប្រវត្តិដែលជាមូលដ្ឋានគ្រឹះនៃក្របខណ្ឌច្បាប់ អ.វ.ត.ក ដូចបានរៀបរាប់លម្អិតខាងលើ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ | **លោកស្រី** **Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

កថាខណ្ឌ១៦-១៧ (សម្រេចថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក អាចត្រូវបានរំលត់តែអនុលោមតាមវិធាន ៨៩(១)(ខ)នៃវិធានផ្ទៃក្នុង ផ្អែកលើទឡ្ហីករណ៍មួយនៃទឡ្ហីករណ៍ដែលបានកំណត់ដូចមានចែងក្នុងមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប៉ុណ្ណោះ)។